HAMILTON-WENTWORTH DISTRICT SCHOOL BOARD

# Safe & Caring SCHOOLS 3

# ការចូលចិត្តសម្លុតធ្វើបាបគេ (BULLYING)

## ព័ត៌មានសំរាប់ឪពុកម្តាយនិងកូនសិស្ស (Information for Parents and Students)

---

Hamilton-Wentworth District School Board

គណកម្មការបានខិតខំព្យាយាមធ្វើកិច្ចការបំរើយ៉ាងយកចិត្តទុកដាក់ជាទីបំផុតដល់គ្រប់សាលាទាំងអស់ដើម្បីធ្វើយ៉ាងណាឲ្យសាលាទាំងនោះមានសេចក្តីសុខគ្រប់ៗទីកន្លែងសំរាប់ការរៀនសូត្រ។







www.hwdsb.on.ca/programs/safeschools

ALL STUDENTS ACHIEVING THEIR FULL POTENTIAL

## មាតិការឿង (Table of Contents)

តើអ្វីទៅជាមនុស្សដែលចូលចិត្តធ្វើបាបសម្លុតគេ? 3
ប្រភេទនៃរូបភាពមនុស្សចូលចិត្តធ្វើបាបសម្លុតគេ 3
តើត្រូវធ្វើដូចម្តេចបើសិនជាកូនរបស់អ្នកត្រូវបានគេធ្វើបាបសម្លុតមើលងាយ 4
តើត្រូវធ្វើដូចម្តេចបើសិនជាកូនលោកអ្នកជាក្មេងដែលចូលចិត្តធ្វើបាបសម្លុតគេ 5
តើត្រូវធ្វើដូចម្តេចបើសិនជាកូនរបស់លោកអ្នកជាអ្នកឈរមើលគេធ្វើអំពើរបាប 5
ពត៌មានបន្ថែម (Additional Information)
បរិវេណសាលាដែលមានសន្តិសុខល្អ (Positive School Climate) 6
វិន័យនៃអាកប្បកិរិយា (Code of Conduct) 6
ថែរក្សាសិស្សរបស់យើងឲ្យមានសេចក្តីសុខនៅសាលា (គម្រោងច្បាប់ 157) 6
(Keeping Our Kids Safe at School) (Bill 157)
គណកម្មការសន្តិសុខសាលា (Safe-School Committee) 6
សហការណ៏ជាមួយមន្ទីរផ្សេងៗក្នុងសហគមន៍ 6
(Partnerships with Community Agencies)
ពត៌មានធនធានបន្ថែមសំរាប់ឳពុកម្តាយនិងសិស្ស 7
(Additional Resources for Parents and Students)

សិស្សនិមួយៗគួរតែមានអារម្មណ៏ថា មានសេចក្តីសុខនិងមានសន្តិសុខនៅឯសាលា
នៅជុំវិញបរិវេណសាលារៀន
នៅលើរថយន្តក្រុងនិងកន្លែងប្រារព្ធពិធីផ្សេងៗនិងសកម្មភាពនៅសាលារៀន។ នៅឯ Hamilton-Wentworth District School Board (HWDSB)
យើងដឹងហើយថាសន្តិសុខសាលាគឺមានសារៈសំខាន់ណាស់សំរាប់ការរៀនសូត្ររបស់សិស្ស។
សិស្សរៀនឆាប់ចេះ
រីឯលោកគ្រូអ្នកគ្រូវិញក៏ទទួលបានជោគជ័យច្រើនក្នុងការបង្រៀនសិស្សពេលសាលាមានសន្តិសុខ។
ប្រសិនបើសិស្សមិនស្តាប់បង្គាប់លោកគ្រូអ្នកគ្រូទេ
លោកចាងហ្វាងនឹងសំរាច់ថាតើត្រូវធ្វើដូចម្តេចដើម្បីជួយកូនសិស្សឲ្យ
អាចកែប្រែចរិកចរិយារបស់ពួកគេ។

ចរិកចរិយាអាចកត់សំគាល់ថាកូនរបស់លោកអ្នកគឺជាមនុស្សដែលចូលចិត្តធ្វើបាបសម្លុតគេឬយ៉ាងណា។





### តើអ្វីទៅជាមនុស្សដែលចូលចិត្តធ្វើបាបសម្លុតគេ? (What is Bullying?)

មនុស្សដែលចូលចិត្តធ្វើបាបសម្លុតគេគឺជាប្រភេទនៃអាកប្បកិរិយាគឃ្លើនឈ្លានពានដែលធ្វើឡើងដដែលៗ
មិនព្រមឈប់ឈរ
ហើយអាកប្បកិរិយាគឃ្លើននោះគឺធ្វើឡើងសំដៅទៅកាន់មនុស្សណាម្នាក់ឬមួយច្រើននាក់ដែលត្រូវទទួលរង
នូវអំពើរនោះ (តាមការដឹងគឺអ្នកទទួលរង), ធ្វើឲ្យភ័យខ្លាច
កើតទុក្ខព្រួយឬមួយធ្វើឲ្យមានគ្រោះថ្នាក់ដល់រូបរាងកាយ ប៉ះពាល់ផ្លូវចិត្ត បាត់បង់ភាពថ្លៃថ្នូរ
ខូចកេរ្តិ៍ឈ្មោះ។ មនុស្សចូលចិត្តធ្វើបាបសម្លុតគេតែងតែធ្វើឡើងក្នុងរូបភាពដែលអាចមើលឃើញថា
មានអំណាចមិនស្មើគ្នា។

- សិស្សដែលចូលចិត្តធ្វើបាបសម្លុតគេនោះច្រើនប្រើអំណាចដើម្បីគ្រប់គ្រងនិងធ្វើឲ្យអ្នកដទៃកើតទុក្ខព្រួយ
- សិស្សដែលត្រូវគេធ្វើបាបសម្លុតនោះមានការបាត់បង់អំណាចបន្តិចម្តងៗហើយក៏ជួបប្រទះនូវទំនាក់ទំនងមួយដែល មានតែការធ្វើទុក្ខបុកម្នេញ។
- សិស្សប្រើអំណាចជាច្រើនយ៉ាង:
    - មាឌ កំលាំង ប្រាជ្ញាស្មារតី អាយុ
    - ឋានៈក្នុងសង្គម
    - វណ្ណៈទ្រព្យធន
    - ការយល់ដឹងពីចំណុចខ្សោយខ្វះខាតរបស់មនុស្សម្នាក់ទៀត
    - ជាសមាជិកក្នុងក្រុមរបស់អ្នកមានវណ្ណៈខ្ពស់

### ប្រភេទនៃអាកប្បកិរិយារបស់អ្នកដែលចូលចិត្តធ្វើបាបសម្លុតគេ (Types of Bullying Behaviours)

រាងកាយ: **(Physical)** វាយធ្វើបាបជារឿយៗ ទាត់ធាក់ រុញច្រាន វាយធ្វើបាប លួចឆក់
ឬធ្វើឲ្យខូចខាត ទ្រព្យសម្បត្តិអ្នកដទៃ

ពាក្យសំដី: **(Verbal)** ហៅឈ្មោះរបៀបមើលងាយ សើចចំអក បញ្ឈឺចិត្ត លលេង គំរាមកំហែង
និយាយពាក្យប្រកាន់ពូជសាសនិងការរំខានផ្លូវភេទ

សង្គម: **(Social)** សម្លក់សំឡឹងធ្វើភ្នែកក្រឡើតក្រឡាប់ មិនឲ្យអ្នកដទៃចូលរួមក្នុងក្រុមជាមួយ
និយាយចាក់រុក និយាយដើមគេ និយាយពាក្យចចាមអារាម
ធ្វើឲ្យអ្នកណាម្នាក់ហាក់ដូចជាមនុស្សឆ្កួតលីលាហើយនិងធ្វើឲ្យប៉ះពាល់
ដល់ការរាប់អានរបស់អ្នកណាម្នាក់

អេលិកត្រូនិក សាយបឺ **(Electronic/Cyber):** ការប្រើប្រាស់អ៊ីម៉ែលញឹកញាប់ជារឿយៗ ទូរស័ព្ទដៃ
ផើធិក ប្រើឧបករណ៍អិនធឺណិតនិងវ៉ែបសៃដើម្បីគំរាមកំហែង
ធ្វើឲ្យខ្មាស់គេឬមួយធ្វើឲ្យខូចកេរ្តិ៍ឈ្មោះនិងចំណងមិត្តភាព

ប្រកាន់ពូជអំបូរ: **(Racial)**

- ប្រើអាកប្បកិរិយាគគ្រីនឈ្លានពានដដែលៗជាញឹកញាប់ មិនចុះសម្រុងជាមួយគេឯងឬមួយនិយាយពាក្យសំដីអ្វី មិនសមរម្យដាក់អ្នកណាម្នាក់ឬមនុស្សច្រើននាក់ព្រោះតែប្រកាន់ពូជសាសឬជាតិសាសឬទំនៀមទម្លាប់មិនដូចគ្នា
- ហៅឈ្មោះរបៀបមើលងាយមនុស្សណាម្នាក់ឬច្រើននាក់ញឹកញាប់ជារឿយៗឬសើចចំអកពូជសាសឬជាតិសាសឬ វប្បធម៌ប្រពៃណី។

សាសនា: **(Religious)**

- ប្រើអាកប្បកិរិយាគគ្រីនឈ្លានពានដដែលៗញឹកញាប់ មិនចុះសំរុងជាមួយគេឯងឬមួយនិយាយពាក្យមិនសមរម្យ ដាក់អ្នកណាម្នាក់ឬមនុស្សច្រើននាក់ព្រោះតែជំនឿសាសនារបស់គេ ប្រវត្តដើមរបស់គេរបៀបស្លៀកពាក់ឬមួយ ការគោរពខ្ជាប់ខ្ជួនឬប្រកាន់នូវទម្លាប់
- ហៅឈ្មោះរបៀបមើលងាយមនុស្សម្នាក់ឬមនុស្សច្រើននាក់ឬមួយសើចចំអកអំពីជំនឿសាសនារបស់គេ ប្រវត្តដើម របៀបស្លៀកពាក់ឬមួយការគោរពខ្ជាប់ខ្ជួនប្រកាន់នូវទម្លាប់

ការរួមភេទ: **(Sexual)**

- ដើរចេញពីមនុស្សម្នាក់ឬមនុស្សច្រើននាក់ញឹកញាប់ជារឿយៗឬរាប់អានពួកគេយ៉ាងតោះតើយបំផុតពីព្រោះតែភេទឬ មួយលក្ខណៈរូបរាងកាយមនុស្សនោះ
- ប្រើពាក្យសំដីទ្រគោះបោះបោកអំពីការរួមភេទរបស់មនុស្សនោះ ប្រើពាក្យសំដីអំពីភេទមនុស្សឬកំប្លែងលេង ប៉ះពាល់ ចាប់ឬប៉ះរាងកាយអ្នកណាម្នាក់ក្នុងផ្លូវស្នេហា
- ដើរផ្សព្វផ្សាយពាក្យចចាមអារាមដដែលៗអំពីមនុស្សម្នាក់ឬមនុស្សច្រើននាក់
- ហៅឈ្មោះអ្នកណាម្នាក់ថាគេជាមនុស្សដែលប្រតិព័ទ្ធនឹងភេទដូចគ្នា ស្ត្រីដែលប្រតិព័ទ្ធស្ត្រីភេទដូចគ្នាឬមួយដាក់ងារ ឈ្មោះមិនសមរម្យ

ពិការភាព: **(Disability)**

- មិនព្រមរាប់បញ្ចូលមនុស្សម្នាក់ឬមនុស្សច្រើននាក់ដដែលៗឬមើលងាយគេយ៉ាងអាក្រក់បំផុតពីព្រោះតែពិការភាព មើលទៅដូចជាមានភាពពិការឬមួយត្រូវការសិក្សាពិសេសអ្វីមួយ
- និយាយពាក្យសំដីឬកំប្លែងលេងដដែលៗដើម្បីធ្វើឲ្យមនុស្សពិការឈឺចាប់

ចំពោះពត៌មានបន្ថែមស្តីអំពីច្បាប់របស់ (HWDSB)

និងវ៉ែបសៃសូមមើលទំព័រតាមឧបករណ៍អិនធឺណិតដូចតទៅ:
www.hwdsb.on.ca/aboutus/policies

តើត្រូវធ្វើដូចម្តេចបើសិនជាកូនរបស់អ្នកត្រូវបានគេធ្វើបាបសម្លុត: **(What to do if your child is being bullied)**

- និយាយជាមួយកូនៗដើម្បីឲ្យបានជ្រាបអំពីជីវិតរបស់ពួកគេ
- ស្តាប់អំពីការរៀបរាប់របស់កូនក្នុងមួយថ្ងៃៗរួមទាំងការទៅសាលានិងមកពីសាលានិងព្រឹត្តិការណ៍ផ្សេងៗនៅសាលា
- និយាយជាមួយលោកគ្រូអ្នកគ្រូឬចាងហ្វាងសាលារបស់កូនប្រសិនបើអ្នកគិតថាកូនរបស់អ្នកត្រូវបានមនុស្សដែល ចូលចិត្តធ្វើបាបគេនោះធ្វើបាប
- លើកទឹកចិត្តកូនរបស់អ្នកឲ្យនិយាយប្រាប់មនុស្សចាស់ណាដែលកូនយើងទុកចិត្តនៅឯសាលាហើយគាត់អាចជួយ បញ្ឈប់ការធ្វើបាបសម្លុតនោះបាន
- លើកទឹកចិត្តកូនឲ្យចេះធ្វើម្ចាស់ការលើខ្លួនឯងហើយព្យាយាមកុំការពារអោបក្រសោបកូនខ្លាំងពេក
- បង្រៀនកូនឲ្យរាប់អានមិត្តភ័ក្រថ្មី ប្រុងស្មារតីជានិច្ចអំពីបរិដ្ឋានជុំវិញខ្លួនហើយត្រូវតែក្លាហានកុំខ្លាចគេ
- លើកទឹកចិត្តឲ្យមានសកម្មភាពកំសាន្តណាមួយដែលធ្វើឲ្យមានភាពជឿជាក់លើខ្លួនឯង
- គួរស្វែងរកជំនួយបើសិនជាអ្នកព្រួយបារម្ភអំពីកូនរបស់អ្នកដែលអាចមានបញ្ហាខួរក្បាល

បណ្តាំខ្លះៗសំរាប់ឳពុកម្តាយ: (**Tips for Parents**) សូមពិនិត្យមើលវ៉ែបសៃរបស់យើង www.hwdsb.on.ca/programs/safeschools សំរាប់ពត៌មានបន្ថែមទៀត.

តើត្រូវធ្វើយ៉ាងណាបើសិនជាកូនរបស់អ្នកជាក្មេងចូលចិត្តធ្វើបាបសម្លុតគេ: **(What to do if your child is bullying)**

- ត្រូវពិនិត្យបញ្ហាឲ្យបានម៉ត់ចត់
- និយាយជាមួយកូនរបស់អ្នកអំពីអាកប្បកិរិយា ត្រូវចងចាំថាកូនក្មេងដែលចូលចិត្តធ្វើបាបសម្លុតគេនោះគឺតែងតែរករឿងស្តីបន្ទោសលើអ្នកដទៃជានិច្ច
- និយាយប្រាប់កូនរបស់អ្នកថាអ្នកនឹងមិនអាចទទួលយកអាកប្បកិរិយានេះទេ អ្នកត្រូវរៀបចំរបៀបស្លូតធម៌ត្រជាក់ មិនប្រើធម៌ក្តៅទេឲ្យសំទៅនឹងអ្វីដែលកូនរបស់អ្នកបានធ្វើរួចហើយ
- ពិភាក្សាអំពីផលអាក្រក់នៃអាកប្បកិរិយាទៅលើអ្នកដទៃ
- ផ្តល់ការលើកទឹកចិត្តឬបង្ហាញពីភាពទន់ភ្លន់ទៅកាន់អ្នកដទៃដើម្បីបង្ហាញថាអ្នកឲ្យតម្លៃអាកប្បកិរិយានោះយ៉ាងណា
- បង្រៀនពួកគេអំពីមធ្យោបាយដោះស្រាយបញ្ហាដោយមិនចាំបាច់ប្រើពាក្យសំដីឬសកម្មភាពអ្វីមួយ
- កុំឲ្យពួកគេឃើញអាកប្បកិរិយាសាហាវរវាងសមាជិកគ្រួសារឲ្យសោះ
- ចំណាយពេលវេលាជាមួយកូនៗជាពិសេសធ្វើសកម្មភាពផ្សេងៗនិងចៀសវាងគំរូអាក្រក់ឬពត៌មានអំពីអំពើរព្រៃផ្សៃ
- មើលការខុសត្រូវឲ្យបានល្អពេលណាកូនរបស់អ្នកនៅជាមួយមិត្តភ័ក្រ ហើយគួរតែឃាត់កុំឲ្យកូនចងចំណងមិត្តភាព ជាមួយមិត្តភ័ក្រច្រលឹមកោងកាច
- និយាយជាមួយលោកគ្រូអ្នកគ្រូឬចាងហ្វាងរបស់កូនអ្នកប្រសិនបើអ្នកគិតថាកូនរបស់អ្នកមានបញ្ហាទទួលខុសត្រូវលើ ទង្វើរដែលគេបានធ្វើ
- ស្វែងរកជំនួយប្រសិនបើអ្នកបារម្ភអំពីបញ្ហាខួលក្បាលរបស់កូនអ្នក។

តើត្រូវធ្វើយ៉ាងណាបើសិនជាកូនរបស់អ្នកជាអ្នកឈរមើលមនុស្សដែលចូលចិត្តធ្វើបាបសម្លុតធ្វើសកម្មភាពធ្វើបាបគេ **(What to do if your child is a bystander of bullying)**

- បង្រៀនពួកគេឲ្យចេះយល់ចិត្តអ្នករងគ្រោះ (យល់ពីអារម្មណ៍ជនរងគ្រោះ)
- ជួយពួកគេឲ្យយល់ថាមានការខុសគ្នារវាង "ការពិតទូល" និង "ការរាយការណ៍"
- គួរទៅជាមួយកូនពេលទៅជួបលោកគ្រូអ្នកគ្រូឬចាងហ្វាងសាលាដើម្បីរាយការណ៍អំពីអ្វីដែលពួកគបានឃើញ
- បង្រៀនកូនរបស់អ្នកឲ្យចេះចូលរួមជាមួយអ្នកដទៃដើម្បីជួយការពារកូនក្មេងណាដែលត្រូវបានគេធ្វើបាបសម្លុត

ពន្យល់ពីឥទ្ធិពលអាក្រក់សំរាប់រយៈពេលវែងក្នុងសង្គមដែលអាចកើតមានឡើងដល់ក្មេងដែលត្រូវ
 គេធ្វើបាបសម្លុត បើសិនជាការធ្វើបាបសម្លុតនោះមិនត្រូវបានគេបញ្ឈប់ទេនោះ
លើកទឹកចិត្តកូនឲ្យរាប់អានមិត្តភ័ក្រណាដែលគួរឲ្យគោរពនិងមានចិត្តល្អ
 ហើយគួរតែបញ្ឈប់ទំនាក់ទំនងជាមួយ អ្នកដែលធ្វើឲ្យមានការឈឺចាប់
គួរធ្វើជាគំរូខាងចិត្តល្អប្រពៃនិងមានចិត្តក្លាហានមុះមុត

ពត៌មានបន្ថែម **(Additional Information)**

ទីកន្លែងសាលាមានស្ថានភាពល្អប្រសើ **(Positive School Climate)**
សាលារៀនដែលមានភាពល្អឥតខ្ចោះអាចកើតឡើងបានពេលណាសមាជិកនៃសាលាទាំងអស់មានអារម្មណ៍ថាមានសន្តិសុខ មានភាពកក់ក្តៅហើយត្រូវបានគេទទួលស្គាល់។
សាលារៀនទាំងអស់មានកម្មវិធីផ្សេងៗដែលអាចជួយលើកស្ទួយនិងគាំទ្រ
អាកប្បកិរិយាល្អហើយវាឆ្លុះបញ្ចាំងពីជំហានដំបូងនៃលក្ខណៈកិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាលការសិក្សារបស់ Hamilton-Wentworth District School Board

វិន័យនៃអាកប្បកិរិយា **(Code of Conduct)**
វិន័យនៃអាកប្បកិរិយាដែលគូសបញ្ជាក់ពីក្តីសង្ឃឹមនិងភារកិច្ចរបស់បុគ្គលិក សិស្ស ឪពុកម្តាយ
រួមទាំងអ្នកមកសួរសុខទុក្ខ គឺមានគ្រប់ៗសាលា។ គណកម្មការវិន័យនៃអាកប្បកិរិយាមានដូចតទៅ
www.hwdsb.on.ca/programs/safeschools

ថែរក្សាកូនចៅរបស់យើងឲ្យមានសេចក្តីសុខនៅសាលា **(Keeping Our Kids Safe at School) (Bill 157)**
បុគ្គលិកគណកម្មការដែលធ្វើការផ្ទាល់ជាមួយសិស្សគឺតម្រូវឲ្យឆ្លើយតបទៅនឹងហេតុការដែលអាចមានផលប៉ះពាល់ទៅលើ ស្ថានភាពនៅសាលា។
បុគ្គលិកទាំងអស់គឺតម្រូវឲ្យរាយការណ៍ទៅលោកចាងហ្វាងបើសិនជាគេបានដឹងថាមានសិស្សណា
ម្នាក់ប្រហែលជាមានសកម្មភាពអ្វីមួយអាចធ្វើឲ្យសិស្សត្រូវបញ្ឈប់ឬមួយសំរាកពីការរៀនសូត្រមួយរយៈ។
ការធ្វើបាបសម្លុត គឺជាចរិកចរិយាមួយដែលត្រូវយកការបញ្ឈប់មកគិតគូរពិចារណា។
លោកចាងហ្វាងត្រូវទូរស័ព្ទទំនាក់ទំនងជាមួយឪពុក
ម្តាយរបស់សិស្សដែលទទួលរងគ្រោះពីរឿងហេតុដែលកើតឡើង។

គណកម្មការសន្តិសុខសាលា **(Safe-School Committee)**
សាលានិមួយៗមានគណកម្មការសន្តិសុខសាលា។
គណកម្មការសន្តិសុខសាលាប្រើពត៌មានទាក់ទងដែលទទួលបានមក
ពីចរិកចរិយានៃការធ្វើបាបសម្លុតដើម្បីឃ្លាំមើលនិងពិនិត្យសើរើផលប៉ះពាល់នៃកម្មវិធីសាលាការពារការធ្វើបាបសម្លុត។ ការទទួលបានពត៌មានរាប់បញ្ចូលទាំងពត៌មានស្តីពីកម្រងសំណួរសាលា
ពត៌មានស្តីពីការបញ្ឈប់និងការសំរាកមួយរយៈ
យោបល់របស់សិស្ស គំនិតយោបល់ឪពុកម្តាយ។ល។

សហការណ៍ជាមួយមន្ទីរផ្សេងៗក្នុងសហគមន៍ **(Partnerships with Community Agencies)**
Hamilton-Wentworth District School Board
បន្តធ្វើសកម្មភាពយ៉ាងសកម្មជាមួយដៃគូសហគមន៍ដែលជួយសាលា
និងសហគមន៍រកដំណោះស្រាយលុបបំបាត់ការធ្វើបាបសម្លុតក្នុងបរិដ្ឋានរបស់យើងគ្រប់ទីកន្លែងទាំងអស់។



ធនធានបន្ថែមសំរាប់ឪពុកម្តាយនិងសិស្ស **(Additional Resources for Parents and Students)**

លោកអ្នកអាចទូរស័ព្ទទាក់ទងលោកចាងហ្វាងឬអនុចាងហ្វាងនៅឯសាលារបស់កូនលោកអ្នក។
លោកអ្នកអាចទូរស័ព្ទ ភ្នាក់ងារទទួលខុសត្រូវខាងផ្នែកគ្រប់គ្រងសាលារៀន។

ពត៌មានបន្ថែមអំពីការឲ្យឱវាទប្រហែលជាអាចទទួលបានតាមរយៈដូចតទៅនេះ:
(Further counselling information may be available through the following:)

- វេជ្ជបណ្ឌិតប្រចាំគ្រួសារ
- ទូរស័ព្ទទាក់ទងតាមរយៈហាមិលថុន Hamilton 905-570-8888 ឬមួយ info@contacthamilton.ca
- ពិគ្រោះសុំយោបល់ពីអ្នកសង្គមកិច្ចសាលា
- ពិគ្រោះសុំយោបល់ពីអ្នកជំនាញចិត្តសាស្រ្តឲ្យយោបល់ផ្នែករៀនសូត្រ
- ប្រហែលជាអាចទទួលពត៌មានបានតាមរយៈអ្នកធ្វើការខាងជួយសម្របសម្រួលដល់ជនអន្តោប្រវេសន៍អ្នកចំណូលថ្មី
  និងអាចជួយក្នុងការទំនាក់ទំនងនៅសាលាដោយយល់ពីទុក្ខធុរៈឬមួយអាចបញ្ជូនទៅរកជំនួយនៅតាមកន្លែងផ្សេងៗក្នុងសហគមន៍និងទទួលបាននូវធនធានសំខាន់ៗតាមសេចក្តីត្រូវការ។

ពត៌មានបន្ថែមតាមអិនធឺណិតដូចតទៅនេះ: (Further information online is available through)

- www.bullyfreehamilton.ca
- www.PrevNet.ca
- www.maccura.ca
- បណ្ណាល័យសាធារណៈទីក្រុងហាមិលថុន (Hamilton Public Library): www.hpl.ca
- បណ្តាញសន្តិសុខសាលា (Canadian Safe Schools Network): www.canadiansafeschools.com
- ក្រសួងសិក្សាធិការ (Ministry of Education): www.edu.gov.on.ca/eng/safeschools/publications.html

*សូមគួសចំណាំ: កូនសៀវភៅនេះគឺមានបំណងសំរាប់ការផ្តល់ពត៌មាន។*
*វាមិនមែនសំរាប់ការឲ្យដំបូន្មានផ្នែកផ្លូវច្បាប់ទេ។*



# Safe & Caring SCHOOLS 3

មានកូនសៀវភៅជាច្រើនទៀតផ្នែកមានសន្តិសុខនិងការយកចិត្តទុកដាក

1. វិន័យនៃអាកប្បកិរិយា (Code of Conduct)
2. បន្តការប្រដៅទូន្មាន (Progressive Discipline)
3. ការចូលចិត្តធ្វើបាបសម្លុត (Bullying)
4. ការបញ្ឈប់ឬសំរាកមួយរយះ (Suspension)
5. ការបណ្តេញចេញពីសាលា (Expulsion)
6. មធ្យោបាយបន្តនៃការកែប្រែចរិកចរិយាឲ្យបានស្អាតស្អំ (Gateway)
7. ស្លៀកសំលៀកបំពាក់ឲ្យបានត្រឹមត្រូវ (Appropriate Dress)
8. ពិនិត្យពេលមកដល់ដើម្បីសន្តិសុខ (Safe-Arrival Check)

HAMILTON-WENTWORTH DISTRICT SCHOOL BOARD

**Hamilton-Wentworth District School Board**
**100 Main Street West**
**Hamilton, ON L8P 1H6**
**905-527-5092**

**www.hwdsb.on.ca/programs/safeschools**

ALL STUDENTS ACHIEVING THEIR FULL POTENTIAL